**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខៈ ១.៣៦២ ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៤

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាអន្តរក្រសួង ដើម្បីកំណត់អត្តសញ្ញាណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម ក្នុងការអនុវត្តរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោកវរសេនីយ៍ឯក **ឃៀង សុគន្ធា** | អនុប្រធាននាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២- | លោក **គាត ពុធណារិទ្ធិ** | ប្រធានការិយាល័យព័ត៌មានវិទ្យា នៃបេឡាជាតិរបបសន្តិសុខសង្គម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- | លោកវរសេនីយ៍ទោ **ឈុន វណ្ណា** | នាយការិយាល័យព័ត៌មានប្រជាសាស្ត្រ នាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- | លោកវរសេនីយ៍ត្រី **ឈិន គំសន់** | នាយរងការិយាល័យព័ត៌មានប្រជាសាស្ត្រនាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥- | លោក **ឌី សួរ** | អនុប្រធានការិយាល័យព័ត៌មានវិទ្យា នៃបេឡាជាតិរបបសន្តិសុខសង្គម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦- | លោក **ហាំង សុខសេរី** | អនុប្រធានការិយាល័យព័ត៌មានវិទ្យា នៃបេឡាជាតិរបបសន្តិសុខសង្គម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៧- | លោកស្រីអនុសេនីយ៍ទោ **រឿម វណ្ណី** | នាយរងផ្នែកដ្ឋាល នាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិកា |
| ៨- | លោកអនុសេនីយ៍ត្រី **សំអុន ជំនិត** | នាយរងផ្នែកបង្កើតកម្មវិធីនាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- | កញ្ញា **ង៉ា លក្សី** | មន្ត្រីនៃបេឡាជាតិរបបសន្តិសុខសង្គម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |

**ប្រការ២.-**

ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាមានភារកិច្ចដូចខាងក្រោម៖

១-រៀបចំនីតិវិធី និងបែបបទនៃការកំណត់អត្តសញ្ញាណកម្មករនិយោជិតដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម។

២-ភ្ជាប់បណ្តាញព័ត៌មានវិទ្យារវាងនាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ជាមួយបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ និងទទួលទិន្នន័យបញ្ជាក់អត្តសញ្ញាណកម្មករនិយោជិតក្នុងរបបធានារ៉ាប់រងសុខភាព។

៣- សិក្សាស្រាវជ្រាវលើកផែនការថវិកាសម្ភារៈបច្ចេកទេស ដើម្បីធានាដល់ការគ្រប់គ្រងទិន្នន័យកម្មករនិយោជិត រវាងនាយកដ្ឋាននគរបាលស្តិត និងលិខិតឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ជាមួយ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៤- សហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ រៀបចំផែនការ ដើម្បីផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អោយបានត្រឹមត្រូវតាមនីតិវិធី ជូនកម្មករនិយោជិត ដែលស្ថិតក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ។

៥- សហការ និងសម្របសម្រួលការងារជាមួយអ្នកជំនាញការជាតិ អន្តរជាតិ ដែលពាក់ព័ន្ធ ដើម្បីធានាឱ្យការ បំពេញភារកិច្ចបានប្រព្រឹត្តទៅដោយរលូន។

៦- ធ្វើរបាយការណ៍ស្តីពីសភាពការណ៍ និងលទ្ធផលការងារប្រចាំខែជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ករណីចាំបាច់ត្រូវធ្វើរបាយការណ៍វិសាមញ្ញ ដើម្បីក្រសួងមានគោលការណ៍ និងចាត់វិធានការដោះស្រាយទាន់ពេលវេលា។

**ប្រការ ៣.-**

អនុប្រធាន សមាជិក និងសមាជិកាទាំងអស់ នៃក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យានេះត្រូវចូលរួមប្រជុំតាមការ អញ្ជើញរបស់ប្រធាន។

**ប្រការ ៤.-**

រាល់ការចំណាយសម្រាប់កិច្ចដំណើរការនៃក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាជាបន្ទុករបស់បេឡាជាតិរបបសន្តិ សុខសង្គម។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គស្នងការនគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ នានា នៃក្រសួងមហាផ្ទៃ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុក អនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ិត សំហេង

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ